# សារអបអរសាទររបស់ឯកឧត្តម ឯកអគ្គរាជទូត គូម៉ាម៉ារូ យូជិ
# ក្នុងពិធីប្រគល់លិខិតសរសើរពីរដ្ឋមន្ត្រីការបរទេសជប៉ុន
# ជូនលោក តេហ្សឹកា កូជិ លោកស្រី ឡុច លក្ខ័ស្មី លោក កូយ៉ាម៉ា កេនជិ

សូមគោរព

- ឯកឧត្តមបណ្ឌិត ពិត ចំណាន រដ្ឋលេខាធិការក្រសួងអប់រំយុវជន និង កីឡា
- ឯកឧត្តមបណ្ឌិត ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំយុវជន និង កីឡា
- លោកតេហ្សឹកា កូជិ ទីប្រឹក្សានៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
- លោកស្រី ឡុច លក្ខ័ស្មី ប្រធានដេប៉ាតឺម៉ង់ភាសាជប៉ុន នៃវិទ្យាស្ថានភាសាបរទេស សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- លោក កូយ៉ាម៉ា កេនជិ ចុងភៅនៅនិវេសនដ្ឋានឯកអគ្គរាជទូត
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និង ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានរៀបចំពិធីប្រគល់លិខិតសរសើរពីរដ្ឋមន្ត្រីការបរទេសជប៉ុន ដោយមានវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងកម្មវិធីនេះ។ សូមអបអរសាទរ លោកតេហ្សឹកា លោកស្រីឡុច លក្ខ័ស្មី និង លោកកូយ៉ាម៉ាដែលទទួលបានលិខិតសរសើរនាឱកាសនេះ។

ខ្ញុំសូមជម្រាបជូនពីស្នាដៃរបស់លោក លោកស្រីដែលទទួលបានលិខិតសរសើរដូចតទៅ។

លោកតេហ្សឹកា កូជិ ទីប្រឹក្សានៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បានចូលធ្វើការក្នុងអង្គការសន្តិស្ម័គ្រចិត្ត(SVA) កាលពីឆ្នាំ១៩៨៤ និងត្រូវបានចាត់មកធ្វើការនៅការិយាល័យទីក្រុងបាងកក។ បន្ទាប់មកលោកបានទទួលខុសត្រូវផ្នែកកិច្ចការយុវជននៅជំរុំជនភៀសខ្លួនកម្ពុជាខាងអ៊ីដាងនៃព្រំដែនកម្ពុជា-ថៃ ហើយលោកក៏បានខិតខំប្រឹងប្រែងសាងសង់សាលារៀនសម្រាប់កុមារ បង្កើតបណ្ណាល័យ និង កន្លែងបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។

នៅឆ្នាំ១៩៩១ ស្របពេលដែលអង្គការSVA បានបង្កើតការិយាល័យនៅកម្ពុជា លោកបានប្តូរមកកម្ពុជា ជានាយករង បន្ទាប់មកជានាយកការិយាល័យ ហើយក៏បានជួយក្នុងវិស័យអប់រំកម្ពុជាយ៉ាងសកម្ម។ ក្រោយពេលលោកធ្វើការជាអគ្គលេខាធិការនៃអង្គការSVAនៅទីក្រុងតូក្យូមួយរយៈ លោកត្រូវបានចាត់តាំងមកកម្ពុជាជាថ្មីម្តងទៀតក្នុងនាមជាទីប្រឹក្សានៃអង្គការSVA នៅឆ្នាំ២០០៥។

ចំពោះទំនាក់ទំនងជាមួយសង្គមជនជាតិជប៉ុននៅកម្ពុជា លោកក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតសមាគមជនជាតិជប៉ុនក្នុងឆ្នាំ១៩៩១ និងការគ្រប់គ្រងសមាគមនេះ។ លោកធ្លាប់ធ្វើជាប្រធានសមាគម២ដង ក្នុងរយៈពេល៥ឆ្នាំ ហើយធ្វើជាសមាជិកគណៈកម្មការគ្រប់គ្រងក្នុងរយៈពេល៧ឆ្នាំ។ ហើយបច្ចុប្បន្ននេះ លោកធ្វើជាប្រធានសមាគមនេះម្តងទៀត។ ចំពោះការបង្កើតសាលាជនជាតិជប៉ុន លោកបានធ្វើជាប្រធានគណកម្មការរៀបចំក្នុងរយៈពេល២ឆ្នាំ ចាប់ពីឆ្នាំ២០១៣ ហើយក៏បានចូលរួមសម្របសម្រួលជាមួយស្ថាប័ននានានៅកម្ពុជាដើម្បីបង្កើតសាលានេះឡើង។ បន្ទាប់ពីសាលាជនជាតិជប៉ុននេះចាប់ផ្តើមមានដំណើរការ ក្នុងនាមលោកជាប្រធានរដ្ឋបាលនៃសាលានេះ លោកក៏កំពុងរួមចំណែកក្នុងការអប់រំកុមារជប៉ុននៅកម្ពុជាផងដែរ ។

នៅឆ្នាំ២០១៤ លោកបានចូលនិវត្តន៍ពីអង្គការសន្តិស្មុំគ្រចិត្ត(SVA) ហើយបច្ចុប្បន្នលោកជាទីប្រឹក្សានៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យកម្ពុជា។

លិខិតសរសើរក្នុងថ្ងៃនេះ ប្រគល់ជូនលោកតេហ្សឹកា ដែលលោកបានធ្វើការដើម្បីកម្ពុជាក្នុងរយៈពេល៣២ឆ្នាំ និងរួមចំណែកជម្រុញការយល់ដឹងគ្នាទៅវិញទៅមករវាងជប៉ុន និង កម្ពុជាយ៉ាងធំធេង។ ខ្ញុំសង្ឃឹមថា តាមរយៈឱកាសនេះ សកម្មភាពអង្គការជប៉ុន កាន់តែមានភាពរីកចម្រើន ហើយនឹងធ្វើឲ្យទំនាក់ទំនងមិត្តភាពនៃប្រទេសយើងទាំងពីរជប៉ុន និងកម្ពុជាកាន់តែស៊ីជម្រៅបន្ថែមទៀត។

ចំពោះលោកស្រី ឡុច លក្ខ័ស្មី ប្រធានដេប៉ាតឺម៉ង់ភាសាជប៉ុន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចាប់ផ្តើមរៀនភាសាជប៉ុន ក្នុងឆ្នាំ១៩៩៤ នៅថ្នាក់ភាសាជប៉ុន ដែលអ្នកស្ម័គ្រចិត្តJICA បានបង្កើតឡើងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្នុងឆ្នាំ១៩៩៨ លោកស្រីបានទទួលជ័យលាភីលេខ១ ក្នុងការប្រឡងប្រជែងថ្លែងសុន្ទរកថាភាសា

ជប៉ុនលើកទី១។ ចាប់តាំងពីឆ្នាំនោះមក លោកស្រីបានក្លាយជាសាស្ត្រាចារ្យថ្នាក់ភាសាជប៉ុន។ នៅឆ្នាំ២០០៥ លោកស្រីត្រូវបានតែងតាំងជាប្រធានដេប៉ាតឺម៉ង់ភាសាជប៉ុនលើកដំបូងដែលត្រូវបានបង្កើតឡើង នៅវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ដេប៉ាតឺម៉ង់នេះ គឺជាដេប៉ាតឺម៉ង់ភាសាជប៉ុន ដែលសិក្សាថ្នាក់បរិញ្ញាបត្រតែមួយគត់នៅកម្ពុជា។ មិនតែប៉ុណ្ណោះ លោកស្រីបានដើរតួនាទីដែលគ្មានអ្នកណាអាចប្រៀបបាន ក្នុងការជម្រុញការអប់រំភាសាជប៉ុន ដូចជាការចូលរួមក្នុងការបង្កើតសមាគមគ្រូបង្រៀនភាសាជប៉ុនកាលពីឆ្នាំ២០០៧ និងធ្វើជាប្រធានសមាគមដោយផ្ទាល់។

ចាប់ពីឆ្នាំ២០១០មក លោកស្រីបានចូលរួមចំណែកបង្កើនអ្នកសិក្សាភាសាជប៉ុន ហើយបានបង្ហាញអំពីប្រទេសជប៉ុនតាមរយៈការបង្កើតកម្មវិធី "កម្មសិក្សាផ្សព្វផ្សាយវប្បធម៌ និង ភាសាជប៉ុន" នៅតាមវិទ្យាល័យនានាទូទាំងប្រទេស។ លោកស្រីក៏បានរួមចំណែកដល់ការផ្លាស់ប្តូររវាងប្រទេសយើងទាំងពីរ ដូចជា ការចុះអនុស្សារណៈយោគយល់គ្នាជាមួយសាកលវិទ្យាល័យជប៉ុនចំនួន១៣ ដើម្បីការផ្លាស់ប្តូរនិស្សិតទៅវិញទៅមក។

ខ្ញុំសង្ឃឹមថា តាមរយៈសកម្មភាពរបស់លោកស្រី ការអប់រំភាសាជប៉ុននៅកម្ពុជានឹងមានការរីកចម្រើនបន្ថែម ហើយកូនសិស្សរបស់លោកស្រីនឹងក្លាយជាស្ពានចំណងមិត្តភាពនៃប្រទេសយើងទាំងពីរ ហើយការយល់ដឹងពីគ្នាទៅវិញទៅមកនៃប្រទេសយើងទាំងពីរនឹងកាន់តែមានភាពស៊ីជម្រៅបន្ថែមទៀត។

ចំពោះលោក កូយ៉ាម៉ា គេនជិ ចុងភៅនៅនិវេសនដ្ឋានឯកអគ្គរាជទូតជប៉ុន បានរៀន និងហ្វឹកហាត់ជំនាញធ្វើម្ហូបជប៉ុន រយៈពេល១៣ឆ្នាំនៅទីក្រុងក្យូតូ បន្ទាប់មកលោកបានបើកហាងដោយខ្លួនលោកផ្ទាល់នៅខេត្តមិអិដែលជាស្រុកកំណើតរបស់លោក។ ដោយសារលោកមានបំណងចូលរួមចំណែកអភិវឌ្ឍ និង ផ្សព្វផ្សាយវប្បធម៌ម្ហូបជប៉ុននៅបរទេស ទើបលោកមកធ្វើជាចុងភៅនៅនិវេសនដ្ឋានឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា។

នៅទីនេះ លោកបានទទួលពាក្យសរសើរជាច្រើនពីម្ហូបដ៏មានឱជារស រួមទាំងសោភ័ណភាពដ៏ទាក់ទាញនៃអាហារ ពីភ្ញៀវដែលបានចូលរួមពិធី ដែលខ្ញុំបានរៀបចំ

នៅនិវេសនដ្ឋាននេះ។
លើសពីនេះទៀត លោកបានបង្ហាញទៅកាន់ប្រជាជនកម្ពុជាទូទៅអំពីអាហារជប៉ុន តាមរយៈការចូលរួមក្នុងពិធីបុណ្យអូដូរី ដែលរៀបចំដោយសមាគមជនជាតិជប៉ុន និង កម្មវិធីដាក់បង្ហាញពី ម្ហូបជប៉ុនក្នុង "មហាស្រពគីហ្សូណា" ដែលសហការរៀបចំដោយ ស្ថានទូតជប៉ុន និង មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន ហើយក៏បានចូលរួម បង្ហាញពីរបៀបធ្វើម្ហូបជប៉ុនក្នុងកម្មវិធីទូរទស្សន៍CTN ជាដើម។
អាហារដែលរៀបចំក្នុងថ្ងៃនេះ ក៏ធ្វើឡើងដោយ លោក កូយ៉ាម៉ាផងដែរ ដូច្នេះសូមឯក ឧត្តម លោកជំទាវ លោក លោកស្រីអញ្ជើញពិសាអាហារដែលជាស្នាដៃរបស់លោកកូ យ៉ាម៉ា ដោយក្ដីរីករាយ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោក កូយ៉ាម៉ា ដែលលោក នៅតែបំពេញការងារ ទោះបីជាពិធីនេះជាពិធីសម្រាប់លោកផ្ទាល់ក៏ដោយ។

សារជាថ្មីម្ដងទៀត ខ្ញុំសូមអបអរសាទរ និង សូមជូនពរ លោកតេហ្សឹកា លោកស្រី ឡូច លក្ខ័ស្មី និង លោកកូយ៉ាម៉ាទទួលបាននូវសុខភាពល្អនិងជោគជ័យបន្ថែមទៀត។